ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ១.៩៥០ហិកតា ក្នុងដែនជម្រកសត្វព្រៃភ្នំសំកុស ស្ថិតក្នុងភូមិសាស្ត្រស្រុកវាលវែង ខេត្តពោធិសាត់ និងនិរាករណ៍ អនុក្រឹត្យលេខ ១២៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០១០

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៧៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព
- បានឃើញអនុក្រឹត្យលេខ ១២៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ២០១០ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ១.៩៥០ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំសំកុស ស្ថិតក្នុងភូមិសាស្ត្រស្រុកវាលវែង ខេត្តពោធិសាត់
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល ។

# សម្រេច

**មាត្រា១.-**

ត្រូវបាននិរាករណ៍អនុក្រឹត្យលេខ ១២៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ២០១០ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ១.៩៥០ហិកតា ក្នុងដែនជម្រកសត្វព្រៃភ្នំសំកុស ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកវាលវែង ខេត្តពោធិសាត់។

**មាត្រា២.-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ១.៩៥០ហិកតា(មួយពាន់ប្រាំបួនរយហាសិបហិកតា)ក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំសំកុស ស្ថិតក្នុងភូមិសាស្ត្រស្រុកវាលវែង ខេត្តពោធិសាត់ ក្រោមល័ក្ខខ័ណ្ឌជួល ឬសម្បទាន ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យ ដាំដំណាំកសិ-ឧស្សាហកម្ម (ដំណាំកៅស៊ូ) ដែលមានទីតាំង និងនិយាមកាដូចមានក្នុងផែនទីភ្ជាប់នឹងលិខិតលេខ ១៤៩០ សជណ.កស ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ២០១០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៣.-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា២នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងបន្ត ដោយក្រសួងបរិស្ថានជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តពោធិសាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ